**សុន្ទរកថា**

**ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

**ថ្លែងក្នុងឱកាសបិទសន្និសីទជាតិស្តីពី**

**ការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ**

**ខេត្តកំពង់ចាម ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧**

សូមគោរព :

- **ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី**
- **លោកស្រី** Jovita M. Corpuz **តំណាង** APRACA
- **លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីស្នេហា !**

មកដល់ពេលនេះ សន្និសីទជាតិស្តីពីការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិរបស់យើង ដែលបានប្រព្រឹត្តទៅអស់រយៈពេលមួយថ្ងៃ បានឈានចូលដល់ពេលដែលត្រូវបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតំលៃយ៉ាងខ្ពស់ថា អង្គសន្និសីទនេះបានប្រព្រឹត្តទៅប្រកបដោយលទ្ធផលផ្លែផ្កា និងដោយជោគជ័យ ក្រោមកិច្ចពិភាក្សាគ្នាយ៉ាងសកម្ម និងផុលផុស។ ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និសីទនេះ ពិតជាក្តាប់បានពីទិដ្ឋភាពរួមនៃគោលនយោបាយ និងក្របខ័ណ្ឌបទប្បញ្ញត្តិចំពោះវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ខ្លឹមសារសំខាន់ៗនៃបទអន្តរាគមន៏ ការផ្លាស់ប្តូរបទពិសោធន៏ ការផ្សព្វផ្សាយព័ត៌មាន និងអនុសាសន៏ផ្សេងៗ ដែលបានឧទ្ទេសនាម និងលើកឡើងដោយតំណាងអាជ្ញាធរអាណាព្យាបាល ពោលគឺធនាគារជាតិនៃកម្ពុជា អាជ្ញាធរដែនដី តំណាងស្ថាប័នអន្តរជាតិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងតំណាងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងសមាជិកសមាជិការបស់អង្គសន្និសីទទាំងមូល។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតំលៃចូលរួមក្នុងអង្គសន្និសីទ ខិតខំយកចិត្តទុកដាក់ស្តាប់ ចូលរួមការពិភាក្សា និងមានវត្តមាននៅទីនេះតាំងពីដើមរហូតដល់ចប់ ។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងនូវសេចក្តីអំណរគុណចំពោះសមាគមឥណទានកសិកម្មជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) និងសមាគមមីក្រូហិរញ្ញវត្ថុ

កម្ពុជាដែលបានផ្តល់កិច្ចសហការឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី និងសម្ភារៈបានធ្វើឱ្យសន្និសីទជាតិស្តីពីការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមអរគុណចំពោះ ការធ្វើចំណាប់អារម្មណ៍របស់តំណាងអាជ្ញាធរដែនដី តំណាងក្រសួងពាក់ព័ន្ធ ស្ថាប័នអន្តរជាតិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តំណាងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងតំណាងកសិករដែលបានចូលរួមផ្តល់កិច្ចសហការ និងជួយរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាឱ្យកាន់តែប្រសើរថែមទៀត ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីស្នេហា**

តាមរយៈស្មារតីនៃអង្គសន្និសីទរយៈពេលមួយថ្ងៃនេះ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់នូវខ្លឹមសារសំខាន់ៗនៃកិច្ចពិភាក្សាចំនួនពីរចំណុច ដូចខាងក្រោម :

ទី១- មតិមួយចំនួនជុំវិញកិច្ចពិភាក្សានៅក្នុងអង្គសន្និសីទ

ទី២- ទិសដៅរយៈពេលខ្លី និងមធ្យមរបស់ធនាគារជាតិនៃកម្ពុជាសំរាប់វិស័យមីក្រូហិរញ្ញវត្ថុ ។

**១. មតិមួយចំនួនជុំវិញកិច្ចពិភាក្សានៅក្នុងអង្គសន្និសីទ**

អង្គសន្និសីទតំបន់នេះបានពិភាក្សាគ្នាដោយផ្តោតទៅលើប្រធានបទសំខាន់ៗ ដូចខាងក្រោម :

**ក). ស្ថានភាពទីផ្សារហិរញ្ញវត្ថុជនបទ និងបទបញ្ញាប្រុងប្រយ័ត្ន**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឥណទានដល់ពលរដ្ឋក្រីក្រ ដើម្បីយកទៅបង្កបង្កើនផល ប្រកបអាជីវកម្ម និងបំពេញតួនាទីជាអន្តរការិយហិរញ្ញវត្ថុខ្នាតតូចនៅតាមតំបន់ដាច់ស្រយាលនៃប្រទេស ក្នុងការអភិវឌ្ឍតំបន់ជនបទ ។

ទោះបីជាយ៉ាងណាក៏ដោយ យើងតែងតែទទួលរងនូវការរិះគន់ថា អត្រាការប្រាក់របស់មីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានកំរិតខ្ពស់ពេក ។ បញ្ហានេះជាការពិតណាស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការនៅតាមតំបន់ជនបទត្រូវប្រឈមមុខនឹងហានិភ័យ និងការប្រើប្រាស់ថ្លៃដើមខ្ពស់ *ដូច្នេះ នាំឱ្យអត្រាការប្រាក់នៃការឱ្យខ្ចីរបស់គេមានកំរិតខ្ពស់ជាងអត្រាការប្រាក់ឱ្យខ្ចីរបស់គ្រឹះស្ថានធនាគារ* ។ ម្យ៉ាងទៀត ប្រភពទុនចំបងដែលត្រូវបានយកមកប្រើប្រាស់សំរាប់ផ្តល់ឥណទាន បានមកពីកំចីពីបរទេស ឬពីកំចីក្នុងស្រុកដែលប្រភពទុនទាំងនោះ ក៏មានតំលៃមួយរបស់វារួចទៅហើយ គឺ *អត្រាការប្រាក់ដែលត្រូវបង់* និងតំលៃមួយទៀតគឺ *អតិផរណា* ។

រយៈពេលបីឆ្នាំចុងក្រោយនេះ យើងទាំងអស់គ្នាបានធ្វើឱ្យអត្រាការប្រាក់បានថយចុះជិតពាក់កណ្តាលបើធៀបទៅនឹងប៉ុន្មានឆ្នាំមុន ។ ជាទិសដៅរបស់យើង គឺធ្វើឱ្យអត្រាការប្រាក់ស្ថិតក្នុងកំរិតសមស្របមួយ ដែល

អ្នកឱ្យខ្ចី និងអ្នកសុំខ្ចីអាចទទួលយកបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មធ្យោបាយនេះមិនមែនជាការកំរិតពិដាននៃអត្រាការប្រាក់នោះទេ គឺគ្រាន់តែជាការជំរុញឱ្យមានការប្រកួតប្រជែងដោយស្មើភាពរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្របតាមយន្តការសេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ ។

ក្នុងនាមជាអាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាមានមុខងារជាអ្នកផ្តល់អាជ្ញាប័ណ្ណ ចេញបទបញ្ញាប្រុងប្រយ័ត្ន និងត្រួតពិនិត្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុទាំងមូល ។

ចំពោះការចេញបទបញ្ញាសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានពិនិត្យពិចារណារកដំណោះស្រាយមួយ ដើម្បីផ្តល់ស្ថានភាពអនុគ្រោះដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអោយរីកលូតលាស់ ដោយមាននិរន្តរភាព និងបង្ការបាននូវហានិភ័យ ។ ប្រតិបត្តិការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ដូចជាសកម្មភាពហិរញ្ញវត្ថុដទៃទៀតដែរ ត្រូវតែមានបទបញ្ញាសមស្រប ដើម្បីជៀសវាងនូវអ្វីដែលអសមត្ថភាព និងភាពមិនទៀងត្រង់ដែលនាំឱ្យអន្តរាយដល់ប្រព័ន្ធ ។ ប៉ុន្តែប្រសិនបើបទបញ្ញាមានការរឹតត្បិតខ្លាំងពេក នោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងធ្វើសកម្មភាពដូចធនាគារ ហើយគេចចេញពីតំបន់ជនបទ មកប្រមូលផ្តុំគ្នាតែនៅតាមទីក្រុងសំខាន់ៗវិញ ។ អាស្រ័យហេតុនេះហើយ បានជាបទបញ្ញាមួយចំនួនដែលដាក់ចេញ ត្រូវមានភាពទន់ភ្លន់ស្របតាមទំហំប្រតិបត្តិការ ឬសកម្មភាពនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

### ខ).បញ្ហាប្រឈមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ទោះបីជាវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងតែរីកចំរើនគួរឱ្យកត់សំគាល់ក៏ដោយ ក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រឈមមុខនឹងបញ្ហាមួយចំនួនផងដែរ ដូចជា កង្វះហិរញ្ញប្បទានជាទុនវិនិយោគ ឬកំចីដែលមានថ្លៃដើមទាបអត្រាការប្រាក់នៅលើទីផ្សារមានកំរិតខ្ពស់ ពុំទាន់មានទីផ្សារទុនក្នុងស្រុកសំរាប់ស្វែងរកប្រភពទុន ហើយការអនុវត្តច្បាប់របស់ប្រព័ន្ធតុលាការក៏នៅមានកំរិត ។ កត្តាទាំងនេះបង្កឱ្យមានការលំបាកដល់គ្រឹះស្ថាន មិនអាចធ្វើការពង្រីកសេវាកម្មរបស់ខ្លួនបាន ទាន់តំរូវការ ។

### គ).បញ្ហាប្រឈមរបស់សហគ្រាសធុនតូច និងមធ្យម

សហគ្រាសធុនតូច និងមធ្យម គឺជាចំណុចគន្លឹះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលរាជរដ្ឋាភិបាលកំពុងផ្តោតការយកចិត្តទុកដាក់បង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយមានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដើរតួនាទីជាអ្នកគ្រប់គ្រងផង ជាអាជ្ញាធរសំរបសំរួលផង និងជាអ្នកកំណត់យុទ្ធសាស្ត្រផង ដើម្បីសហប្រតិបត្តិការជាមួយអ្នកផ្តល់ជំនួយ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីអភិវឌ្ឍន៍គំរោងតំបន់ទន្លេមេគង្គ (MPDF) ក្នុងការជំរុញឱ្យវិស័យនេះមានការរីកចំរើន ។ កន្លងមកសហគ្រាសធុនតូចនិងមធ្យម មានការរីកចំរើនគួរឱ្យកត់សំគាល់ ប៉ុន្តែ មធ្យោបាយផលិតកម្មរបស់សហគ្រាស

នៅមានកំរិត និងខ្វះប្រភពហិរញ្ញវត្ថុសំរាប់ផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះ បំពាក់នូវឧបករណ៍ទំនើបៗ ដែលអាចជួយកាត់បន្ថយថ្លៃដើម និងបង្កើនផលិតភាពថែមទៀត ។

សហគ្រាសធុនតូច និងមធ្យមភាគច្រើន មានការលំបាកក្នុងការទទួលហិរញ្ញប្បទានពីគ្រឹះស្ថានហិរញ្ញវត្ថុ ដូចជា :

- ការផ្តល់ឥណទាន គ្រឹះស្ថានហិរញ្ញវត្ថុផ្តោតលើទ្រព្យដាក់បញ្ចាំ ជាជាងចលនាសាច់ប្រាក់សុទ្ធ
- ថ្លៃដើមនៃទុនសំរាប់សហគ្រាសធុនតូច និងមធ្យមនៅមានកំរិតខ្ពស់នៅឡើយ
- គ្រឹះស្ថានហិរញ្ញវត្ថុពុំទាន់មានទំនុកចិត្តក្នុងការផ្តល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យម ពីព្រោះសហគ្រាសធុនតូច និងមធ្យមពុំមានទ្រព្យដាក់បញ្ចាំ ឬមានឯកសារទ្រព្យដាក់បញ្ចាំច្បាស់លាស់ ។ ឧទាហរណ៍ ដូចជា ការផ្តល់សិទ្ធិកាន់កាប់ដីធ្លីជាដើម ។ ការទទួលខុសត្រូវមិនមានលក្ខណៈស្តង់ដារ គ្មានការចុះបញ្ជិកាច្បាស់លាស់ កង្វះខាតជំនាញវិជ្ជាជីវៈនិងការសិក្សាអប់រំជាមូលដ្ឋានការប្រើប្រាស់ប្រព័ន្ធបច្ចេកវិជ្ជាមិនទាន់សម័យ និងខ្វះព័ត៌មានទីផ្សារដែលធ្វើឱ្យមានចំណាយថ្លៃដើមខ្ពស់ និងពិបាកក្នុងការប្រកួត ប្រជែងលើតំលៃ និងគុណភាព ។

ឆ្លើយតបនឹងបញ្ហាទាំងនេះ រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាដើម្បីជួយដល់សហគ្រាសធុនតូចនិងមធ្យម តាមរយៈការជំរុញឱ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ផ្តល់ឥណទានរយៈពេលវែងនិងសេវាភតិសន្យាដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីឱ្យសហគ្រាសទាំងនោះមានលទ្ធភាពបង្កើនផលិតភាព និងគុណភាពនៃផលិតផលរបស់ខ្លួនដើម្បីប្រកួតប្រជែង ជាមួយផលិតផលបរទេស ។ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ជំរុញឱ្យមានស្ថាប័នភាវូបនីយកម្ម ការបណ្តុះបណ្តាលបុគ្គលិកឯកទេស និងដាក់ចេញនូវគោលនយោបាយមួយចំនួន ក្នុងគោលបំណងបង្កលក្ខណៈអំណោយផលឱ្យសហគ្រាសទាំងនោះរីកលូតលាស់ក្នុងបរិស្ថានល្អប្រសើរ រួមទាំងគោលនយោបាយពន្ធដារអនុគ្រោះផងដែរ ។

### ឃ)_បញ្ហាប្រឈមរបស់កសិករ

ប្រទេសកម្ពុជាមានប្រជាពលរដ្ឋជាង ៨០% គឺជាប្រជាកសិករ ។ ពួកគាត់ប្រើប្រាស់បច្ចេកទេសមិនទាន់សម័យ និងពឹងផ្អែកលើធម្មជាតិក្នុងការប្រកបរបរកសិកម្ម ។ បច្ចុប្បន្ន ទោះបីជារាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបច្ចេកទេសកសិកម្មក៏ដោយ ក៏មិនទាន់ឆ្លើយតបទៅនឹងតំរូវការទាំងស្រុងរបស់ប្រជាកសិករនៅឡើយ ។ លើសពីនេះទៀត ការទទួលបានព័ត៌មានទីផ្សាររបស់ពួកគាត់នៅមានកំរិតនៅឡើយ ដែលធ្វើអោយប៉ះពាល់ដល់ផលិតកម្មនិងប្រាក់ចំណូលរបស់ខ្លួន ។

## ២. ទិសដៅរយៈពេលខ្លី និងមធ្យមរបស់ធនាគារជាតិនៃកម្ពុជាសំរាប់វិស័យមីក្រូហិរញ្ញវត្ថុ

បន្តអនុវត្តតាមអនុសាសន៏ដ៏ខ្ពង់ខ្ពស់របស់ **សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន** ដែលបានថ្លែងក្នុងសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ២០០៦ ។ ក្នុងស្មារតីនៃអនុសាសន៏នោះ គឺតម្រូវឱ្យធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរអាណាព្យាបាលត្រូវ :

*ទី១-* កែលំអបទបញ្ញាប្រុងប្រយ័ត្នសំរាប់ត្រួតពិនិត្យឱ្យកាន់តែមានភាពសុក្រិតឡើង ដើម្បីការពារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យកាន់តែទទួលបានជំនឿទុកចិត្តពីសាធារណជននៅជនបទបន្ថែមទៀត ក្នុងការប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុ ។

*ទី២-* លើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលដែលមិនទាន់ទទួលអាជ្ញាប័ណ្ណ ត្រូវខិតខំពង្រឹងខ្លួនឯង ដើម្បីប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណអាចធ្វើប្រតិបត្តិការនៅក្រោមច្បាប់ត្រឹមត្រូវ ។

*ទី៣-* ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណរួចហើយបន្តពង្រឹងសហគ្រិនភាពរបស់ខ្លួនក្នុងការពង្រីកបណ្តាញប្រតិបត្តិការ និងបង្កើតផលិតផលហិរញ្ញវត្ថុរបស់ខ្លួនថ្មីៗបន្ថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជននៅតំបន់ដាច់ស្រយាលនៃប្រទេសឱ្យទទួលបានឥណទានសំរាប់ពង្រីកមុខរបររបស់ខ្លួន ។

*ទី៤-* យកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលប្រជាពលរដ្ឋ ជាពិសេស ប្រជាពលរដ្ឋក្រីក្រឱ្យយល់ដឹងពីផលប្រយោជន៏នៃការខ្ចីប្រាក់ និងការសន្សំប្រាក់ ការប្រើប្រាស់ប្រាក់ដែលខ្ចី ដើម្បីប្រកបរបរចិញ្ចឹមជីវិតបង្កើនប្រាក់ចំណូល និងលើកស្ទួយជីវភាពរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ។

*ទី៥-* រាជរដ្ឋាភិបាលនៅតែប្រកាន់យកគោលនយោបាយអត្រាការប្រាក់ទីផ្សារ ។ ទន្ទឹមនេះ បន្តលើកទឹកចិត្ត និងផ្តល់កិច្ចសហការជាមួយភាគីពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុ សហគមន៏អន្តរជាតិ និងធនាគារពាណិជ្ជ ដែលបានផ្តល់កម្ចីដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិចារណារិះរកមធ្យោបាយដើម្បីឱ្យអត្រាការប្រាក់កាន់តែថយចុះទាបជាងនេះ ដើម្បីជួយដល់អ្នកក្រីក្ររបស់យើងទាំងអស់គ្នា ។

*ទី៦-* រួមគ្នាបន្តអនុវត្តអនុសាសន៏បន្ថែមចំនួន៤ចំនុចរបស់ **សម្តេច នាយករដ្ឋមន្ត្រី** គឺរក្សាឱ្យបានស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមឱ្យបានល្អ ត្រូវរក្សាកំណើនសេដ្ឋកិច្ចឱ្យកើនបាន ៦%-៧% ធ្វើការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងនិរន្តភាព ។

*ម្យ៉ាងទៀត* ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តប្រព័ន្ធផ្លាស់ប្តូរព័ត៌មានឥណទាន ក្នុងចំណោមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដើម្បីបង្កភាពងាយស្រួលដល់គ្រឹះស្ថានទាំងនោះឱ្យទទួលបានព័ត៌មានឥណទានកាន់តែច្បាស់ពីអតិថិជនរបស់ខ្លួន និងកំពុងខិតខំរៀបចំច្បាប់ស្តីពីឥណទានភតិសន្យា និងបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនទៀត

ដើម្បីបង្កលទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម អាចចូលមកខ្ចីទុនរយៈពេលវែងពីប្រព័ន្ធធនាគារយកទៅប្រើប្រាស់ដើម្បីពង្រីង អាជីវកម្មរបស់ខ្លួន ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីស្នេហា**

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា គឺជាកត្តាគន្លឹះមួយសម្រាប់រួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ **សម្តេច នាយរដ្ឋមន្ត្រី ហ៊ុន សែន** ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ដើម្បីការកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍន៍ វិបុលភាព ភាពសុខដុមរមនា និងសុភមង្គលជូនប្រជាជនកម្ពុជា ។

ខ្ញុំសូមផ្តាំផ្ញើតាមរយៈលោក លោកស្រី ជាអភិបាលស្រុក និងមេឃុំ ដែលជាអាជ្ញាធរអាណាព្យាបាលផ្ទាល់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន មេត្តាជួយពាំនាំនូវស្មារតីនៃអង្គសន្និសីទថ្ងៃនេះយកទៅផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់ លោក លោកស្រី ឱ្យបានយល់ដឹងពីផលប្រយោជន៍ និងភាពងាយស្រួលនៃការទទួលបានឥណទានយកទៅប្រកបមុខរបរចិញ្ចឹមជីវិត តាមរយៈនៃការប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុនៅគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា ។

ខ្ញុំសូមសំដែងនូវអំណរគុណចំពោះប្រតិភូ APRACA ដែលបានផ្តល់កិច្ចសហប្រតិបត្តិការគាំទ្រទាំងផ្នែកស្មារតី និងសំភារៈ ដើម្បីឱ្យអង្គសន្និសីទរបស់យើងថ្ងៃនេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលជាវិជ្ជមាន ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា APRACA និងអាជ្ញាធរមានសមត្ថកិច្ចប្រចាំដែនដីនៅតែបន្តកិច្ចគាំទ្រនិងផ្តល់កិច្ចសហប្រតិបត្តិការទាំងផ្នែកស្មារតី និងបច្ចេកទេស ដើម្បីឱ្យវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងសុវត្ថិភាព ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមក្នុងពិធីនេះ និងសូមជូនពរឱ្យជួបប្រទះតែសេចក្តីសុខ សុភមង្គល និងមានជ័យជំនះគ្រប់ភារកិច្ច ។

ជាសេចក្តីសន្និដ្ឋាន ខ្ញុំសូមគូសបញ្ជាក់ជាថ្មីថា សេវាកម្មមីក្រូហិរញ្ញវត្ថុ គឺជាសេវាដែលផ្សារភ្ជាប់នឹងការគិតគូរខាតចំណេញ ផ្សារភ្ជាប់នឹងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្លួនឯងផ្ទាល់ ផ្សារភ្ជាប់ នឹងការបណ្តុះបណ្តាលមីក្រូសហគ្រិនភាពដល់អ្នកប្រើប្រាស់សេវាឥណទាន ផ្សារភ្ជាប់នឹងការងារមុខរបរ-វិជ្ជាជីវៈ ផ្សារភ្ជាប់នឹងការបង្កើនប្រាក់ចំណូល ផ្សារភ្ជាប់នឹងកំណើនសេដ្ឋកិច្ចនៅជនបទ ហើយតាមរយៈនេះផ្សារភ្ជាប់នឹងការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។

ខ្ញុំសូមបញ្ចប់ ដោយដកស្រង់ពីច្បាប់អរិយសត្ថា ដែលចាស់ទុំបរមបូរាណលោកបានអប់រំកូនខ្មែររាប់សតវត្ស មកហើយថា :

**"វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឱ្យបានដឹងដាន**

**ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ**

**កត់ត្រាបញ្ជី " ។**

ខ្ញុំសូមអរគុណ និងសូមប្រកាសបិទ " **សន្និសីទជាតិស្តីពីការបង្កើតបរិស្ថានគោលនយោបាយហិរញ្ញប្បទានជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ** " ចាប់ពីពេលនេះតទៅ ។